# អំពើហិង្សាក្នុងគ្រួសារ

## យល់ដឹងអំពីសិទ្ធិរបស់អ្នក



សុវត្ថិភាព និង យុត្តិធម៌

# តើអ្វីជាអំពើហិង្សាក្នុងគ្រួសារ ?

អំពើហិង្សាក្នុងគ្រួសារ ជាអំពើរំលោភសិទ្ធិមនុស្ស ។
អំពើនេះ អាចមានច្រើនទម្រង់ ដូចជា៖

១ **អំពើហិង្សាលើរាងកាយ៖**
ការវាយដំ ទាត់ធាក់ ទះកំផ្លៀង រុញច្រាន ច្របាច់ក (ទោះមានរបួស ឬគ្មានក៏ដោយ) ។

២ **អំពើហិង្សាផ្លូវភេទ៖**
អំពើរំលោភសេពសន្ថវៈ (រួមទាំងការរំលោភដោយប្ដី ឬប្រពន្ធ ឬសាច់ញាតិ) អំពើប្រទូស្តកេរខ្មាស សកម្មភាពផ្លូវភេទផ្សេងៗ ដែលគេមិនចង់បាន ។

៣ **អំពើហិង្សាផ្លូវអារម្មណ៍ ឬផ្លូវចិត្ត៖**
អាកប្បកិរិយាបែបគ្រប់គ្រង គំរាមកំហែង រំលោភបំពានដោយពាក្យសំដី ធ្វើឱ្យអាម៉ាស់ តាមដានបែបបៀតបៀន បំផ្លិចបំផ្លាញរបស់របរ ឬឯកោពីគ្រួសារនិងមិត្តភក្តិ ។

៤ **អំពើហិង្សាសេដ្ឋកិច្ច៖**
ការដកហូត/ក្ដាប់ទុក ថវិកា តម្រូវការមូលដ្ឋាន ឬហាមឃាត់ទៅធ្វើការ ឬសាលារៀន ។

# តើនរណាខ្លះរងផលប៉ះពាល់ ?

អំពើហិង្សាក្នុងគ្រួសារ អាចប៉ះពាល់ដល់មនុស្សគ្រប់គ្នា ប៉ុន្តែអំពើនេះ ជារឿយៗ ត្រូវបានប្រព្រឹត្តទៅលើស្ត្រី កុមារ និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI+) ។

# តើនរណាអាចជាជនល្មើស ?

- បច្ចុប្បន្ន ឬអតីត ស្វាមី ភរិយា មិត្តប្រុស ឬមិត្តស្រី ។
- ឪពុកម្តាយ ឬសមាជិកគ្រួសារ ។

# តើមានផលប៉ះពាល់អ្វីខ្លះ ?

អំពើហិង្សាក្នុងគ្រួសារ អាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់រាងកាយ និងផ្លូវចិត្តភ្លាមៗ និងយូរអង្វែង ។ ទោះកុមារមិនបានរងគ្រោះដោយផ្ទាល់ក៏ដោយ ប៉ុន្តែអំពើហិង្សានៅជុំវិញខ្លួនពួកគេអាចប៉ះពាល់ដល់ការលូតលាស់ សុខភាពផ្លូវចិត្ត និងការសិក្សារបស់ពួកគេ ។

**គ្មាននរណាម្នាក់សមនឹងទទួលរង<br>នូវអំពើហិង្សានោះទេ ។**

# តើអំពើហិង្សាក្នុងគ្រួសារ ជាអំពើខុសច្បាប់ឬទេ ?

ពិតណាស់ !

អំពើហិង្សាក្នុងគ្រួសារជាក់លាក់មួយចំនួន គឺជា អំពើខុសច្បាប់ ។ ក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ និងក្រមរដ្ឋប្បវេណី ផ្តល់ការការពារដល់ជនរងគ្រោះ ។



## ជនល្មើសអាចជាប់ពន្ធនាគារពីបទល្មើស៖

| បទល្មើស | ទោសពន្ធនាគារ | ក្រមព្រហ្មទណ្ឌ |
|---|---|---|
| អំពើហិង្សាប្រព្រឹត្ត ដោយសហព័ទ្ធ ឬ អនីតិសង្វាសជន | **២ ដល់ ៥ ឆ្នាំ** | មាត្រា ២២២ |
| បទហិង្សា ដោយចេតនា | **១ ដល់ ៣ ឆ្នាំ** | មាត្រា ២១៧ |
| បទរំលោភសេព សន្ថវៈ ឬ ប៉ុនប៉ង រំលោភសេពសន្ថវៈ | **៥ ដល់ ១០ ឆ្នាំ** | មាត្រា ២៣៩ |
| បទគំរាមកំហែង | **១ ដល់ ៦ ខែ** | មាត្រា ២៣១ |
| បទគំរាមកំហែង ថានឹងសម្លាប់ | **៦ ខែ ដល់ ២ ឆ្នាំ** | មាត្រា ២៣៣ |
| បទឃាតកម្ម ឬ ប៉ុនប៉ងឃាតកម្ម | **១០ ដល់ ១៥ ឆ្នាំ** | មាត្រា ១៩៩ |

**បទល្មើស ឬប្រាក់ពិន័យផ្សេងទៀតអាចជាប់ពាក់ព័ន្ធ ។**

ករណីខ្លះ មានស្ថានទម្ងន់ទោស ដែលអាចដាក់ទោសជាប់ពន្ធនាគាររយៈពេលវែង ។

# តើខ្ញុំមានសិទ្ធិអ្វីខ្លះ ?





- **សិទ្ធិរស់នៅដោយគ្មានអំពើហិង្សា**

- **សិទ្ធិដាក់ពាក្យបណ្ដឹង** ទៅអាជ្ញាធរ

- **សិទ្ធិទាមទារសំណង** តាមរយៈតុលាការ

- **សិទ្ធិស្នើសុំលែងលះ សិទ្ធិចិញ្ចឹមគ្រប់គ្រងកូន ប្រាក់ឧបត្ថម្ភ និងការបែងចែកទ្រព្យសម្បត្តិ** តាមរយៈតុលាការ



- **សិទ្ធិមានមេធាវី** អ្នកអាចស្នើសុំមេធាវីពីអង្គការមិនមែនរដ្ឋាភិបាល សេវាជំនួយផ្នែកច្បាប់ផ្សេងទៀត ឬជួលមេធាវីឯកជន ។

- **សិទ្ធិស្នើសុំសវនាការជាអសាធារណៈ**

- **សិទ្ធិស្នើសុំដីការក្សាការពារ ឬដីកាសម្រេចផ្នែករដ្ឋបាល** ដើម្បីរក្សាសុវត្ថិភាព ។ ជាការល្អ បើអ្នកអាចត្រៀមមធ្យោបាយសុវត្ថិភាពផ្សេងទៀត ដូចជាកន្លែងដែលអ្នកអាចទៅ ឬមនុស្សដែលអាចជួយអ្នកពេលមានអាសន្ន ។

# តើខ្ញុំអាចស្វែងរកយុត្តិធម៌ដោយរបៀបណា ?

អ្នកអាចដាក់ពាក្យបណ្តឹងទៅ៖



១ **នគរបាល (ប៉ូលិស) នៅទីតាំងកើតហេតុ** (ដោយឥតគិតថ្លៃ)

២ **សាលាដំបូងខេត្ត ឬរាជធានី** ដោយផ្ទាល់ទៅព្រះរាជអាជ្ញា

៣ **សាលាឧទ្ធរណ៍** ដើម្បីប្តឹងជំទាស់នឹងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា



**ភស្តុតាងអាចគាំទ្រករណីរបស់អ្នក ។** បើមានសុវត្ថិភាព សូមកត់ត្រាព័ត៌មានលម្អិតពីពេលវេលា និងទីកន្លែងដែលអំពើហិង្សាបានកើតឡើង សាក្សី រូបថតស្នាមរបួស ឬការខូចខាតទ្រព្យសម្បត្តិ លទ្ធផលពិនិត្យ ឬបង្កាន់ដៃពីពេទ្យ សម្លៀកបំពាក់ដែលពាក់ព័ន្ធ ឬសារទំនាក់ទំនងគ្នា ។

# តើប៉ូលិសគួរធ្វើអ្វីខ្លះ ?



**ប៉ូលិសគួរតែ៖**

- **ទទួល និងចាត់វិធានការ លើពាក្យបណ្ដឹងរបស់អ្នក ។** អំពើហិង្សាក្នុងគ្រួសារ ជាបទល្មើសព្រហ្មទណ្ឌ មិនមែនត្រឹមតែជាបញ្ហាក្នុងគ្រួសារទេ ។
- **អន្តរាគមន៍ភ្លាមៗ ដើម្បីបញ្ឈប់អំពើហិង្សា ។** ក្រោយពីទទួលពាក្យបណ្ដឹង ត្រូវស៊ើបអង្កេត ឬបញ្ជូនព័ត៌មានទៅព្រះរាជអាជ្ញា ។
- **ណែនាំអ្នកទៅកាន់សេវាជំនួយនានា** និងបំបែកជនល្មើសពីអ្នកនៅពេលចាំបាច់ ។

**ប៉ូលិសត្រូវទទួលខុសត្រូវ ករណីមិនអនុវត្តតាមតួនាទី ។**
បើប៉ូលិសមិនបញ្ជូនសំណុំរឿង ព្រហ្មទណ្ឌដែលមាន
ភស្តុតាងនៃអំពើហិង្សាក្នុងគ្រួសារ ទៅតុលាការទេ
ប៉ូលិសនោះនឹងត្រូវទទួលទោសតាមច្បាប់
(មាត្រា ៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។

អំពើហិង្សាក្នុងគ្រួសារ មិនមែន
ជាកំហុសរបស់អ្នកទេ ។
អ្នកមិនគួរទទួលរងការស្តី
បន្ទោសពីបញ្ហានេះឡើយ ។



បើអាជ្ញាធរមិនចាត់វិធានការលើពាក្យបណ្តឹង របស់អ្នកទេ អ្នកអាចស្នើសុំប្រឹក្សាយោបល់ពី អង្គការមិនមែនរដ្ឋាភិបាល ឬអាជ្ញាធរពាក់ព័ន្ធ ផ្សេងទៀត ។

# ព័ត៌មានទំនាក់ទំនង

អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) តាមរយៈលេខ៖
**០១២ ៥៣៦ ៣០០ ឬ ០១៥ ៥៥៣ ៨៥៥**

សម្រាប់ព័ត៌មានបន្ថែម
សូមចូលទៅកាន់គេហទំព័រ **សុវត្ថិភាព និង យុត្តិធម៌**
www.licadho-cambodia.org/safety-and-justice

លីកាដូ
LICADHO